# បណ្ណធ្វើដំណើរឥតគិតថ្លៃសម្រាប់យុវជន

យុវជនដែលមានអាយុចាប់ពី 18ឆ្នាំចុះក្រោម អាចជិះរថយន្តក្រុង Pierce Transit ទាំងអស់បានដោយឥតគិតថ្លៃ ដោយអរគុណដល់កញ្ចប់ថវិកាសម្រាប់ការដឹកជញ្ជូនទូទាំងរដ្ឋដែលមានឈ្មោះថា ឆ្ពោះទៅមុខ Washington ( Move Ahead Washington )។ សូមស្វាគមន៍!

**យុវជនទាំងអស់ជិះបានដោយឥតគិតថ្លៃ។ អ្នកជិះដែលមានអាយុចាប់ពី 13ឆ្នាំឡើងទៅ ត្រូវបានលើកទឹកចិត្តឱ្យធ្វើសកម្មភាពណាមួយក្នុងចំណោមចំណុចខាងក្រោមនៅពេលឡើងជិះឡានក្រុង៖**

- ★ សូមយកប័ណ្ណ ORCA សម្រាប់យុវជនរបស់អ្នកទៅប៉ះ។ ( ប័ណ្ណ ORCA សម្រាប់យុវជន ត្រូវបានគេស្គាល់ថាជាប័ណ្ណធ្វើដំណើរឥតគិតថ្លៃសម្រាប់យុវជន។ ចុះឈ្មោះវានៅលើ myORCA.com ដើម្បីធានាថាការជិះដោយឥតគិតថ្លៃត្រូវបានបើករហូតដល់ថ្ងៃខួបកំណើតទី19 របស់អ្នកកាន់ប័ណ្ណ។ បន្ទាប់មក ប័ណ្ណនឹងប្តូរទៅជាប័ណ្ណមនុស្សពេញវ័យដោយស្វ័យប្រវត្តិ។ )
- ★ សូមបង្ហាញប័ណ្ណសម្គាល់ខ្លួនសិស្សវិទ្យាល័យ ឬអនុវិទ្យាល័យបច្ចុប្បន្នរបស់អ្នក

## ទទួលយកកាត!

អ្នកអាចទៅយកប័ណ្ណ ORCA សម្រាប់យុវជនដោយផ្ទាល់នៅមជ្ឈមណ្ឌលសេវាកម្មអតិថិជនរបស់ Pierce Transit ទៅកាន់ 505 E. 25th Street, Tacoma ឬនៅឯបញ្ជររបស់ Pierce Transit, 3701 96th St SW, Lakewood។ អ្នកថែមទាំងអាចកុម្ម៉ង់ប័ណ្ណតាមអនឡាញបានទៀតផង។




**ស្កេនដើម្បីដឹងបន្ថែម**
info.myorca.com/youth-ride-free

នៅជុំវិញតំបន់ Puget Sound យុវជនក៏អាចយកប័ណ្ណធ្វើដំណើរឥតគិតថ្លៃសម្រាប់យុវជន ( ប័ណ្ណ ORCA) របស់ពួកគេទៅប៉ះ និងជិះដោយឥតគិតថ្លៃលើសេវាកម្មរបស់ភ្នាក់ងារដឹកជញ្ជូនផ្សេងទៀតបានផងដែរ។ ស្វែងយល់បន្ថែមនៅ PierceTransit.org/freeyouthpass and myORCA.com។

## គន្លឹះដើម្បីជិះដោយសុវត្ថិភាព

- សូមមកដល់ចំណុចឡានក្រុងមុនម៉ោងដែលឡានក្រុងមកដល់ពីប្រាំទៅដប់នាទី។
- កុំនិយាយមួយមនុស្សចម្លែក។
- សូមទុកឥវ៉ាន់របស់អ្នកឱ្យនៅជិតខ្លួនជានិច្ច។
- សូមរក្សាគម្លាតសុវត្ថិភាពរវាងអ្នក និងឡានក្រុងពេលវាមកដល់។
- សូមរង់ចាំឡើងជិះឡានក្រុងលុះត្រាតែទ្វារបើកអស់ទាំងស្រុង ហើយអ្នកដំណើរដែលមាននៅលើឡានក្រុង មានឱកាសបានចុះ។

## សូមរៀបចំគម្រោងធ្វើដំណើររបស់អ្នកថ្ងៃនេះ

បន្ទាប់មក សូមរៀបចំគម្រោងធ្វើដំណើររបស់អ្នក! អ្នកអាចប្រើប្រាស់កម្មវិធីរៀបចំគម្រោងធ្វើដំណើររបស់យើងនៅ tripplanner.piercetransit.org ឬសាកសួរពីក្រុមសេវាកម្មអតិថិជនរបស់យើងសម្រាប់ជំនួយដោយទូរស័ព្ទទៅ 253.581.8000 ជម្រើសទី2 បន្ទាប់មកជម្រើសទី1។

**ប្រើប្រាស់កម្មវិធីរៀបចំគម្រោងធ្វើដំណើរ**
*tripplanner.piercetransit.org*

**ប្រើកម្មវិធី Transit**
*https://transitapp.com/*

# បទបញ្ញាស្តីពីការជិះឡានក្រុង

## យើងខ្ញុំមានបទបញ្ញាសម្រាប់សុវត្ថិភាពទាំងអស់គ្នា។

### ត្រូវធ្វើ

- អ្នកជិះឡានក្រុងដែលមានអាយុចាប់ពី 19 ឆ្នាំឡើងទៅ ត្រូវតែបង់ថ្លៃសំបុត្រធ្វើដំណើរត្រឹមត្រូវ ហើយត្រូវត្រៀមសំបុត្រធ្វើដំណើរជាស្រេចនៅពេលឡើងជិះឡានក្រុង។
- រក្សាសត្វនៅក្នុងទ្រុងដាក់សត្វដឹកជញ្ជូនសមរម្យ លើកលែងតែសត្វបម្រើការងារសេវាកម្ម។
- ប្រើកាសស្តាប់ត្រចៀក ហើយនិយាយតិចៗនៅខណៈពេលប្រើទូរស័ព្ទ។
- ត្រូវប្រាកដថាចាក់សោហ្វ្រាំងរទេះកង់រុញកូនក្មេង កុំបិទច្រកផ្លូវដើរ ទ្វារ ឬជណ្តើរ។
- រទេះកង់រុញកូនក្មេងត្រូវគ្រប់គ្រងដោយមនុស្សពេញវ័យគ្រប់ពេលវេលា។
- រក្សាកូនៗឱ្យអង្គុយ និងស្ថិតនៅជាមួយលោកអ្នកនៅខណៈពេលធ្វើដំណើរនៅលើឡានក្រុង។
- ស្លៀកសម្លៀកបំពាក់សមរម្យ រួមទាំងអាវ និងស្បែកជើង។
- មានភាពស៊ីវិល័យ និងគោរពអ្នកដទៃ។
- រៀបចំកន្លែងសម្រាប់អ្នកដទៃ នៅពេលឡានក្រុងមានមនុស្សច្រើន។
- គោរពបរិវេណធ្វើដំណើរ។
- ត្រូវប្រាកដថាអាហារ ឬភេសជ្ជៈណាមួយនៅក្នុងកំប៉ុងដែលអាចការពារការហៀរ ឬកំពប់។
- ប្រើប្រាស់កន្លែង និងសេវាកម្មភៀស ត្រានស៊ីត Pierce Transit សម្រាប់ការប្រើប្រាស់ធ្វើដំណើរតែប៉ុណ្ណោះ។
- អនុញ្ញាតឱ្យអ្នកបើកបរយល់ដឹងពីបញ្ហា ឬបុញ្ហាបារម្ភណាមួយដែលលោកអ្នកអាចមាននៅអំឡុងពេលជិះឡានក្រុងរបស់អ្នក។

### មិនត្រូវធ្វើ

- ប្រើគ្រឿងស្រវឹងឬកញ្ឆា។
- ជក់បារី (រួមទាំងបារីអេឡិចត្រូនិច ឬបារីបឺតយកចំហាយផ្សេង) លើកលែងតែនៅកន្លែងដែលបានកំណត់។
- ការនាំយកវត្ថុណាមួយដូចខាងក្រោម៖ ឧបករណ៍ថាមពលឧស្ម័ន សាំង វត្ថុរាវងាយឆេះ កាំជ្រួច គ្រឿងផ្ទុះ ឬសារធាតុដែលស៊ីឬកាត់។
- ចូលរួមសកម្មភាពពាណិជ្ជកម្ម ឬចែកចាយខិត្តប័ណ្ណ សៀវភៅតូចៗ កូនសៀវភៅផ្សព្វផ្សាយ ឬឯកសារសរសេរផ្សេងទៀត ឬប្រមូលហត្ថលេខា លុះត្រាតែមានការអនុញ្ញាតពី លិខិតអនុញ្ញាតស្តីពីការប្រើប្រាស់កន្លែងភៀស ត្រានស៊ីត (Pierce Transit Facilities Use Permit)។
- នាំយកអាវុធខុសច្បាប់ ឬអាវុធផ្សេងៗ។
- រំខាន បៀតបៀនកេរ្តិ៍ខ្មាស ឬរំខានអ្នកដទៃដោយសម្លេងខ្លាំងៗ ការបញ្ចេញសម្លេងខ្លាំងៗ បង្ក គ្រោះថ្នាក់ ការរំលោភបំពាន ហឹង្សា អាកប្បកិរិយាអាសអាភាសឬបៀតបៀនផ្លូវភេទ ការប្រើពាក្យប្រមាថ ឬការធ្វើឱ្យអន់ចិត្ត។

# Connect With Us!

**TRANSLATION SERVICE** is available in more than 200 languages, by calling 253.581.8000, option 2.

Llame al 253.581.8000. Habrá un representante y servicio de traducción en español disponible para atenderle.

Заказать услуги представителя с переводом на русский язык можно по телефону 253-581-8000.

Xin gọi 253-581-8000 để nói chuyện với Nhân Viên Đại Diện Ban Phục Vụ Khách Hàng là người sẽ cung cấp dịch vụ thông dịch Việt Ngữ.

Tawagan ang 253-581-8000 upang makipag-usap sa Representatibo ng Pangserbi syong Kustomer na magbibigay ng serbiyong pagsasalin ng wika sa Tagalog.

한국어 번역 서비스를 제공하는 상담원과 통화하시려면 253-581-8000 으로 전화하십시오.

អាចទំនាក់ទំនងភ្នាក់ងារសេវាបកប្រែភាសាខ្មែរ (កម្ពុជា) ដោយហៅតាមរយៈ លេខទូរស័ព្ទ ២៥៣-៥៨១-៨000 ។

致电 253-581-8000 联系客户服务代表，将提供中文翻译服务。

ចូរចងចាំថា ឡានក្រុងគឺជាធនធានសាធារណៈ ដូច្នេះសូមមានសុជីវធម៌ចំពោះអ្នកដទៃ។ សូមមានការគោរពនៅពេលនៅក្នុងឡានក្រុង និងនៅតាមទីតាំងមធ្យោបាយធ្វើដំណើរនានា។ Pierce Transit ខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យប្រាកដថា ឡានក្រុង និងទីតាំងមធ្យោបាយធ្វើដំណើររបស់ខ្លួន មានភាពស្វាគមន៍ សុវត្ថិភាព និងផាសុកភាពសម្រាប់មនុស្សគ្រប់គ្នា។ អ្នកដែលបំពានច្បាប់នៃការជិះ ឬច្បាប់ដទៃទៀតដែលពាក់ព័ន្ធ អាចនឹងត្រូវបានស្នើសុំឱ្យចាកចេញពីយានយន្ត ឬទីតាំងភ្លាមៗ ហើយអាចនឹងត្រូវបានហាមឃាត់មិនឱ្យប្រើប្រាស់សេវាកម្មដឹកជញ្ជូនក្នុងរយៈពេលណាមួយ។ លើសពីនេះ ប៉ូលិស និង/ឬក្រុមសុវត្ថិភាពរបស់ Pierce Transit ឬភ្នាក់ងារអនុវត្តច្បាប់ក្នុងតំបន់ ក៏អាចចេញដីកាដល់អ្នកដែលបំពានច្បាប់ស្តីពីការប្រព្រឹត្តខុសឆ្គងលើមធ្យោបាយធ្វើដំណើរផងដែរ។ ប្រសិនបើអ្នកមានសំណួរ ឬកង្វល់ណាមួយ សូមផ្ញើអ៊ីមែលមកយើងតាមរយៈ pubsafety@piercetransit.org។

Pierce Transit

253.581.8000 | បញ្ជូនបន្ត 711 | PierceTransit.org

Khmer
កញ្ញា 2025